# ដំណាំពោត



# ដំណាំ ពោត

## I ស្ថានភាពដំណាំពោតនៅប្រទេសកម្ពុជា

ពោតជាដំណាំមួយយ៉ាងសំខាន់ក្នុងចំណោមដំណាំស្បៀងសំខាន់ផ្សេងៗទៀត ។ ដំណាំនេះបានស្ថិតក្នុងចំណាត់ថ្នាក់ទី 3 សំរាប់ការនាំចេញទៅលក់នៅបរទេស បន្ទាប់ពីដំណាំស្រូវនិងកៅស៊ូ ។ ម្យ៉ាងទៀតប្រជារាស្ត្រយើងភាគច្រើននិយមយកពោត ទុកសំរាប់តែប្រើប្រាស់ជាចំណីអាហារបន្ទាប់បន្សំដូចជា ដុត ,ស្ងោរ, សាំង-បន្លែម ។ល។ និងទុកសំរាប់ធ្វើចំណីសត្វប៉ណ្ណោះ។

ដំណាំពោតនេះបានចាប់ផ្តើមដាំនៅប្រ-ទេសកម្ពុជាយើង ចាប់តាំងពីសតវត្សទី 17-18 (សម័យអាណានិគមនិយមបារាំង) ហើយបានឈានឡើងជាចំណាត់ជាតិ ចាប់តាំងពីឆ្នាំ 1910 ។ សព្វថ្ងៃនេះផលិតកម្មដំណាំពោតបានថយចុះយ៉ាងខ្លាំង ដោយសារមានបញ្ហាមួយចំនួនដូចតទៅ :

- គ្រាប់ពោតមានតម្លៃទាប .
- កសិករពុំមានពូជថ្មីគុណភាពល្អ ផ្តល់

ទិន្នផលខ្ពស់ ។

- ដីភាគច្រើនជាប្រភេទដីខ្សោះជីជាតិ ។

ដូច្នេះ ក្នុងឆ្នាំ 1980 - 1984 យើងដាំពោតបានលើផ្ទៃដី 68,7 ពាន់ហិកតា ហើយផលបរិមាណសរុបបាន 67,6 ពាន់តោន ។ នៅអំឡុងឆ្នាំ 1991-92 នេះ យើងដាំបានលើផ្ទៃដី 66 ពាន់ហិកតា ហើយទទួលផលបានប្រ-មាណតែ 60 ពាន់តោន ប៉ុណ្ណោះ ។ ក្នុងជំណោកសេចក្តីត្រូវការគ្រាប់ពោតសំរាប់ទ្វីបអាស៊ី 21 លានតោន នៅឆ្នាំ 1991 - 92 ។

| ប្រភេទពូជ | ឈ្មោះវិទ្យាសាស្ត្រ | អង់គ្លេស | បារាំង |
|---|---|---|---|
| ពោតស | zea Mays | white corn | Mais blanc |
| ពោតបាកែវ | Zea Mays Vra rugosa | Sweetcorn | Mais doux |
| ពោតក្រហម | Zea Mays | Red corn | Mais rouge |

## II សារៈប្រយោជន៍នៃដំណាំពោត

ពោតជាដំណាំពោតមួយប្រភេទយ៉ាងសំខាន់សំរាប់បំរើការ ហូបចុក របស់មនុស្សសត្វ ។

១- ជាចំណីរបស់មនុស្ស

ក/ ជាចំណីអាហារប្រចាំថ្ងៃសំរាប់ប្រទេសមួយចំនួនដែលយកពោតជាអាហារមូលដ្ឋាន ។

ខ/ ជាចំណីអាហារបន្ថែមលើអាហារមូល

ស្ពាន ដែលគេបរិភោគបន្ទាប់បន្សំដូចជា នំគ ស្ករ អាំង កែច្នៃធ្វើជាអង្ករពោត ម្សៅពោត នំពោត ។ល។

២- <u>ជាវត្ថុធាតុដើមសំរាប់រោងចក្រ</u> :

- ដើមនិងស្លឹកធ្វើជាក្រដាស, ជ័រ ឬសំរាប់ដុត
- គ្រាប់ពោតដំណើបកិនជាម្សៅ ធ្វើជាកាវ គ្រឿងតម្បាញ សាប៊ូ ផលិតផលសំរាប់រំលាយលោហធាតុ ។ល។
- គ្រាប់ពោតក្របាមកិនធ្វើជាចំណីសត្វ
- ចម្រាញ់យកជាតិប្រូតេអ៊ីន និងអាមីដុង ធ្វើជាទិសង ។
- កែច្នៃជានំប៉័ង នំប៉ាស្ទី ប្រេងឆា ទឹកសេរ៉ូ ។ល។

៣- <u>សំរាប់ការងារស្រាវជ្រាវវិទ្យាសាស្ត្រ</u>

តាមរយៈដំណាំពោត អាចអោយអ្នកវិទ្យាសាស្ត្រងាយស្រួលសិក្សាពីលក្ខណៈបន្តពូជ និងលក្ខណៈប្រែប្រួលនៃពូជពីជំនាន់មួយទៅជំនាន់មួយ (Hereditary variations) នៃរុក្ខជាតិ ។ នៅក្នុងគ្រាប់ពោត មានសារជាតិផ្សេងៗដូចជា: ជាតិទឹក 10,8% ជាតិប្រូតេអ៊ីន 10,0% ជាតិប្រេង 4,3% ជាតិកាបូអ៊ីដ្រាត 73,4% ជាតិរ៉ែ 1,4% ។ល។

# III - លក្ខណៈរូបសាស្ត្រនៃដំណាំពោត

ដំណាំពោតជារុក្ខជាតិមួយបែបដែលមានអាយុកាលលូតលាស់ខ្លីល្មមសមស្របនឹងការដាំដុះ គឺរយៈពេល 85ថ្ងៃ 90ថ្ងៃ 100ថ្ងៃ 110ថ្ងៃ 130ថ្ងៃ និងរហូតដល់ 185ថ្ងៃ ។ ចំពោះពូជពោតនៅប្រទេសកម្ពុជាយើងច្រើនមានអាយុកាល 85ថ្ងៃ 90ថ្ងៃ និង110ថ្ងៃ ប៉ុណ្ណោះ ។

ជាទូទៅដើមពោតច្រើនមានកំពស់ពី 1,50ម ទៅ 3,00ម ។ ដោយឡែកនៅអាមេរិកខាងត្បូង កំពស់ពោតមានរហូតដល់ 9ម ។

ពោតមានស្លឹករាងជាបន្ទះស្រួចវែង មានបណ្តោយប្រមាណជា 1ម ទទឹងពី 7-15ស.ម ស្លឹកវាបានដុះចេញពីថ្នាំង និងតំរៀបឆ្លាស់គ្នាពីមួយទៅមួយ ។ លក្ខណៈពិសេសចំពោះដំណាំនេះ គឺនៅលើដើមពោតតែមួយមានផ្កាញី និងផ្កាឈ្មោលនៅជាមួយគ្នា តែផ្កាឈ្មោលស្ថិតនៅផ្នែកខាងលើនៃដើម និងផ្កាញីស្ថិតនៅចំពាក់កណ្តាលដើម ។ ដូច្នេះផ្កាញីជាកន្លែងកំណើតនៃផ្លែពោតនេះឯង ។

## IV - បច្ចេកទេសដាំដុះ

### ១- ការជ្រើសរើសពូជ

- គ្រាប់ពូជល្អ ផ្តល់ទិន្នខ្ពស់
- គ្រាប់ពូជល្អ ដែលមានភាពសុទ្ធលើសពី 95%
- គ្រាប់ពូជដែលមានអត្រាដំណុះលើសពី 85%
- គ្រាប់ពូជថ្មី មិនទុកយូរខែឆ្នាំពេក ។
- គ្រាប់ពូជធន់ទ្រាំនឹងជំងឺ សត្វល្អិតបំផ្លាញ និងមិនប្រេះបែក ។

### ២- រដូវកាលដាំដុះ

នៅតំបន់ត្រូពិក ពោតជាដំណាំមួយដែលមិនរើសរដូវកាលដាំដុះ គឺអាចដាំបានគ្រប់ពេលវេលា ។

ដោយឡែកនៅប្រទេសកម្ពុជា គេអាចដាំពោតបានល្អនៅតាមបណ្តាខេត្តមួយចំនួនតាមដងទន្លេដូចជា: ខេត្តកណ្តាល , ព្រៃវែង , កំពង់ចាម, ក្រចេះ , កំពង់ឆ្នាំង និងតំបន់ដីក្របាម ។

ចំពោះដីនៅតាមមាត់ទន្លេ គេអាចដាំបានក្នុង 1ឆ្នាំ 2ដង ព្រោះជាតំបន់ដែលអាចធានាបានទឹកនិងជីជាតិបានគ្រប់គ្រាន់ ។

- រដូវវស្សា: ចាប់ពីចុងខែមេសា ដល់

ពាក់កណ្ដាលខែឧសភា និងប្រមូលផលនៅចុង ខែសីហា ចំពោះតំបន់ដីតាមមាត់ទន្លេ និងចាប់ពីខែឧសភា ដល់ខែកក្កដា និងប្រមូលផលនៅចុងខែ កញ្ញា ចំពោះនៅតំបន់ដីក្រហម ។

- រដូវប្រាំង : នាំបានចាប់ពីរដូវទឹកស្រក គឺចាប់តាំងពីខែវិច្ឆិកា រហូតដល់ខែមករា ហើយប្រមូលផលនៅចុងខែមិនា និងដើមខែមេសា ។

៣- <u>ការរៀបចំដី</u> :

- នៅរដូវប្រាំង ការភ្ជួររាស់ដី ត្រូវអោយបានម៉ត់ល្អ ដើម្បីរក្សាសំណើមក្នុងដីបានយូរ ហើយអាច ភ្ជួរដីបាលត្រឹមតែ 5 - 15 ថ្ងៃប៉ុណ្ណោះ ។

- សំរាប់រដូវវស្សាវិញ គេពុំចាំបាច់ធ្វើដីអោយម៉ត់ពេកទេ ព្រោះអាចបណ្ដាលអោយដីដាប់ ហាប់ បន្ទាប់ពីភ្លៀងធ្លាក់ ។ ការភ្ជួរបាលដីដំពោតក្នុងរដូវនេះ ត្រូវធ្វើអោយបានពី 1 ខែ ទៅ 2 ខែ ដើម្បីសម្លាប់ស្មៅចង្រៃ , សត្វល្អិត ឯម្បី ព្រមទាំងបង្កើនបន្ទុកខ្យល់ក្នុងដីអោយបានល្អថែមទៀត ។

៤- <u>របៀបដាក់ជី</u> :

លើកទី 1 : ដាក់ជីទ្រាប់បាតក្នុងផ្ទៃដី 1 ហិកតា

- ជីលាមកសត្វចំនួនពី 5 - 10 តោន ភ្ជួរលប់មុនពេលដាំ

- អ 15.15.15 ឬ 16-20-0 ចំនួនពី 200-300 គ.ក្រ ។

លើកទីពីរ : ជីអ៊ុយរ៉េ ដាក់នៅពេលពោតចេញស្លឹក 6-8 សន្លឹក ឬនៅពេលពូនគល់លើកទី 2 ។

ចំពោះប្រភេទជីគីមី វត្ថុធាតុអាសូតគេអាចដាក់ពី 50-150 គ.ក្រ ក្នុង 1 ហិកតា ។ ផូស្វ័រពី 30-90 គ.ក្រក្នុង 1 ហិកតា និងវត្ថុធាតុប៉ូតាសពី 50-130 គ.ក្រក្នុង 1 ហិកតា ។

វត្ថុធាតុគីមីដែលត្រូវដាក់តាមដំណាក់កាលលូតលាស់របស់ពោត :

| ពេលវេលាដែលត្រូវដាក់ | បរិមាណនៃវត្ថុធាតុគីមី N-P-K | របៀបដាក់ជី |
|---|---|---|
| ដាក់ពេលភ្ជួររាស់មុនដាំ ឬ ដាក់រាយពេលដាំ | 25.30%-100%-100% | ដាក់ទ្រាប់បាត |
| ពេលពោតមានអាយុកាលលូតលាស់30ថ្ងៃនៅពេលពូនគល់លើកទី 2 | 50-70%-0%-0% | ដាក់បំប៉ន |

* <u>សេចក្តីបញ្ជាក់</u>: ដាក់ជីទ្រាប់បាតមានពីរយ៉ាងគឺ ភ្ជួរលុបមុនពេលដាំ និងដាក់នៅពេលដាំដោយរាយនៅក្បែរគ្រាប់ ចម្ងាយប្រហែល5ស.ម ។ ចំពោះជីបំប៉ន ត្រូវដាក់រាយនៅក្បែរគល់ប្រហែល 5 ស.ម រួចពូនគល់លប់ដៃគូង ។

ជម្រៅគ្រាប់ដែលត្រូវកប់ ឬ បុកដាំ គឺអា-ស្រ័យដោយសភាពសំណើមដែលមាននៅក្នុងដី ចំពោះដីសើម ឬ នៅរដូវវស្សា ការកប់ ឬ បុកដាំគ្រាប់ពោតរាក់ល្មមគឺប្រមាណ 3-5 ស.ម ។ ចំណែកដីស្ងួត ឬ នៅរដូវប្រាំងវិញ ការកប់ ឬ បុកដាំគ្រាប់ពោត ត្រូវកាយជ្រៅបន្តិចគឺប្រ-មាណពី 5-8 ស.ម ។



## V - ការថែទាំ :

ក. ការរំលស់កូន : ក្រោយពេលដាំឬកប់ដីបាន 2-3 ថ្ងៃ ក៏ពេលគ្រាប់ពោតចាប់ផ្ដើមចេញពន្លក បើឃើញគ្រាប់ដែលមិនដុះមានតិចជាង 10% យើងមិនចាំបាច់រំលស់ទេ តែបើគ្រាប់មិនដុះមានច្រើន ត្រូវប្រញាប់រំលស់គ្រាប់ថ្មីជាបន្ទាន់ ដើម្បីធានាបាននូវចំនួនដើមក្នុងផ្ទៃដី 1 ហិកតា និងដើម្បីធានាបរិមាណផលបានច្រើន ។

ខ - ការដកបំបែកកូនពោត : ក្រោយពេលកូនពោតដុះបាន 15 ថ្ងៃ ឬនៅពេលកូនពោតមានស្លឹក 3-4 សន្លឹក មានកំពស់ប្រមាណ 10-15 ស.ម ត្រូវប្រញាប់ដកបំបែកដើមចេញខ្លះទុកតែ 1 ដើមឬ 2 ដើម នៅតាមចន្លោះរន្ធ និងចន្លោះគុម្ពខាងលើ ។ ដើមដែលទុក ត្រូវរើសយកដើមណាដែលថ្លោស មានភាពរឹងមាំដុះលូតលាស់ល្អជាងគេ ។ បើទុកដើមច្រើនក្នុងមួយគុម្ពៗនោះ ពោតដុះមិនស្មើគ្នា ខាតជីជាតិ ដើមវែងស្គមៗ ផ្ដល់ផ្លែតូច ឬគ្មានផ្លែ ឬមានផ្លែដែរតែមិនសូវដាក់គ្រាប់ណែនល្អ ។

គ- ការជ្រួយដី ដកស្មៅ ពូនគល់ :

- ក្រោយពេលដកបំបែកកូនពោតពេល

ខ្ទះហើយ ត្រូវដាប់បន្ថែមដោចស្មៅ ស្រួយដីនិង
ពូនគល់លើកទី 1 ដើម្បីអោយដីធូរ ដក់សំណើម
បានច្រើន ឫសពោតនិងបានល្អ ខ្យល់ចេញចូល
បានស្រួល ។

- ពេលពោតមានអាយុ 40 ថ្ងៃ ឬឃើញ
ពោតចេញស្លឹកបានពី 6 - 8 សន្លឹក ត្រូវចៃង
ស្មៅដាក់ដី និងពូនគល់វាលើកទី 2 ដើម្បី
អោយឫសថ្មីដុះបន្ថែមទៀត និងអោយ
ពោតនិងលូតលាស់បានល្អ ។ វាទូទៅយើង
អាចដាំរះស្មៅ ពូនគល់ពី 3 - 4 ដង ក្នុងរដូវ
វស្សា និងពី 1 - 2 ដងនៅរដូវប្រាំង ។ បើ
យើងបណ្ដោយអោយស្មៅដុះច្រើននោះ
មិនផលពោតនិងថយចុះ ព្រោះវាដណ្ដើមជី
វាតពីពោត ។ ម្យ៉ាងទៀត ស្មៅវាជាជំរក
លាក់ខ្លួនរបស់សត្វចង្រៃ មួយចំនួន ដូចជាសត្វ
សត្វកណ្ដុរជាដើម ។ល។

## VI ការប្រមូលផល :

យើងអាចសន្និដ្ឋានថា ផ្លែពោតទុំដោយ
ផ្អែកលើលក្ខណៈបីយ៉ាង :

១- អាយុកាលរបស់ប្រភេទពូជនិមួយៗ
២- លក្ខណៈរូបរបស់ដើម ពេលមានពណ៌

លឿង ហើយក្រៀមស្វិត ស្លឹកពណ៌លឿងទុំ ដូចស្លឹកឈើងាប់ សំបកផ្លែស្ងួតក្រៀមស្រួយ ដូចក្រដាស សាក់វាឡើងឮស្រួយ គ្រាប់ភ្លឺរលោង ហើយរឹង ។

៣ - សំណើមក្នុងគ្រាប់មានតិចជាង 25% នៅពេលប្រមូលផល ។

ភ្នំពេញ ថ្ងៃទី ១២ មករា 1995

រៀបរៀង និងចងក្រងដោយ

- លោក ផន់ - ខេង

ប្រធានស្ថានីយ៍ ជ្រើសរើសនិងផលិតពូជពោតបន្ទាយដែក ។

- លោក ឌៅ សម្ភារ

វិស្វករក្សេត្រវិទ្យា

- កែសំរួលដោយ គណៈកម្មការចងក្រងអក្ខរបទ បច្ចេកទេស នាយកដ្ឋាន - ក្សេត្រសាស្ត្រ ។

ផ្សាយចេញពីនាយកដ្ឋានក្សេត្រសាស្ត្រ  សហការ
ជាមួយអង្គការទស្សនៈពិភពលោកអន្តរជាតិ (W.V.I)